# នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 18-Feb-2015, 10:31
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹង
## ឯកសារ E327/3

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Marie GUIRAUD

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គឹមសួន

គឹម ម៉េងឃី

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន ស៊ុរិន

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

ចៅក្រម Claudia FENZ

ចៅក្រម យូរ ឧត្តរា

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

សំ សុគង់

វ៉ែន ពៅ

ទី ស្រីនណា

Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Elodie DULAC
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Nushin SARKARATI

**ជនជាប់ចោទ៖**

ខៀវ សំផន

នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

**មេធាវីប្រចាំការ៖**

ទូច វលក្ខណ៍

Calvin SAUNDERS

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖**

Olivier BAHOUGNE
Patrick BAUDOUIN
Beini Ye

## I. សេចក្តីផ្តើម

1. នៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បានចេញឯកសារ E327 ដែលកំណត់អំពីនីតិវិធីដែលត្រូវអនុវត្តចំពោះការកំណត់កាលបរិច្ឆេទសម្រាប់ការជំទាស់ទៅនឹងឯកសារផ្សេងៗនៅក្នុងសំណុំរឿង 00២/0២។ នៅថ្ងៃទី 0២ ខែ កុម្ភៈ ឆ្នាំ ២០១៥ សហមេធាវីការពារក្តីលោក ខៀវ សំផន ("មេធាវីការពារក្តី") បានដាក់ការជំទាស់របស់ខ្លួនលើភាពទទួលយកបាននៃឯកសារមួយចំនួនដែលត្រូវបានស្នើសុំសម្រាប់ការជំនុំជម្រះក្នុងសំណុំរឿង 00២/0២ និងសំណើសុំឱ្យមានកិច្ចពិភាក្សាដេញដោលមួយពិតប្រាកដពាក់ព័ន្ធនឹងតម្លៃជាភ័ស្តុតាង ("ការជំទាស់")[1]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") សូមឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") គួរបដិសេធការជំទាស់របស់មេធាវីការពារក្តី។

## II. ច្បាប់ជាធរមាន

2. វិធានផ្ទៃក្នុងរបស់តុលាការបានផ្តល់ឱ្យអង្គជំនុំជម្រះនូវឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយក្នុងការទទួលយកឯកសារធ្វើជាភ័ស្តុតាង[2] ប្រសិនបើឯកសារនោះបានបំពេញលក្ខណវិនិច្ឆ័យនៃភាពជាប់ពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាពនៃឯកសារ ដែលមានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង[3]។ អង្គជំនុំជម្រះបានសម្រេចថា ភ័ស្តុតាងដែលត្រូវបានយកមកពិចារណា អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ត្រូវតែបំពេញបទដ្ឋាន*នៃសេចក្តីបញ្ជាក់ដំបូង* (*prima facie*)

[1] ការជំទាស់លើភាពទទួលយកបាននៃឯកសារមួយចំនួនដែលត្រូវបានស្នើសុំសម្រាប់ការជំនុំជម្រះក្នុងសំណុំរឿង 00២/0២ និងសំណើសុំឱ្យមានកិច្ចពិភាក្សាដេញដោលមួយពិតប្រាកដ ពាក់ព័ន្ធនឹងតម្លៃជាភ័ស្តុតាង ឯកសារ **E327/3** ថ្ងៃទី 0២ ខែ កុម្ភៈ ឆ្នាំ ២០១៥។

[2] វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិសោធនកម្មលើកទី៨ ថ្ងៃទី 0៣ ខែ សីហា ឆ្នាំ ២០១១ (ចែងថា "លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភ័ស្តុតាងទាំងអស់ត្រូវតែទទួលយក")

[3] វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ដូចខាងលើ (ចែងថា "អង្គជំនុំជម្រះអាចបដិសេធចំពោះពាក្យសុំឱ្យពិនិត្យភ័ស្តុតាង បើយល់ឃើញថា៖ ក) មិនជាប់ពាក់ព័ន្ធ ឬ ជាការស្នើសុំជាន់គ្នា ខ) មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ គ) មិនសមស្របសំរាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង ឃ) ច្បាប់មិនអនុញ្ញាត ឬ ង) មានចេតនាពន្យាកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍")។

នៃភាពជាប់ពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាពនៃឯកសារនោះ[4]។ នៅក្នុងការកំណត់អំពីភាពអាចជឿជាក់បាន អង្គជំនុំជម្រះបានបញ្ជាក់ថា "ទោះបីជាក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក មិនបានតម្រូវក៏ដោយ សូចនាករនៃភាពអាចជឿទុកចិត្តបាន [...] អាចជួយដល់អង្គជំនុំជម្រះនៅក្នុងការវាយតម្លៃថាតើភស្តុតាងដែលលើកឡើង បំពេញលក្ខខណ្ឌនានាដែលមាននៅក្នុងវិធាន ៨៧ (៣) នៃវិធានផ្ទៃក្នុងដែរឬទេ"[5]។

## III. ការពិភាក្សា

3. ឧបសម្ព័ន្ធ ខ នៃការជំទាស់ មានលេខឯកសារជាក់លាក់មួយចំនួនដែលមេធាវីការពារក្តីជំទាស់ចំពោះឯកសារដែលមាននៅក្នុងបញ្ជីឯកសារ និងភស្តុតាងដែលសហមេធាវីនាំមុខបានស្នើឡើង[6] និងសំណើភស្តុតាងថ្មីរបស់សហមេធាវីនាំមុខ[7]។ សហមេធាវីនាំមុខកត់សម្គាល់ថា ពុំមានការផ្តល់

[4] អនុស្សរណៈ អង្គជំនុំជម្រះសាលាដំបូង "ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងផ្នែកខ្លះនៃឯកសារ E114, E114/1, E131/1/9, E131/6, E136 និង E158" ឯកសារ **E162** ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ កថាខណ្ឌ ២។ សូមមើលផងដែរ អនុស្សរណៈ អង្គជំនុំជម្រះសាលាដំបូង "ចម្លើយតបទៅនឹងសំណើតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញា ជនជាប់ចោទ នួន ជា និង ខៀវ សំផន (E236/4/1, E265, E271, E276 និង E276/1)" ឯកសារ **E276/2** កថាខណ្ឌ ២ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (បន្ទាប់ពីនេះទៅហៅថា "អនុស្សរណៈស្តីពីភស្តុតាងថ្មី")។

[5] សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ **E96/7** កថាខណ្ឌ ២៩ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២។ សូមមើលផងដែរ សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន ៩២ ទាក់ទិននឹងសូចនាអំពីការជឿទុកចិត្តចំពោះឯកសារចំនួន ៩៧៨ ដែលជាប់ពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញដែលអាចកោះហៅសម្រាប់សវនាការបីសប្តាហ៍ដំបូង ឯកសារ **E158** កថាខណ្ឌ ៣ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១១ (ផ្តល់ជូននូវបញ្ជីដែលមិនទាន់រៀបរាប់អស់នៅឡើយអំពីសូចនានៃភាពអាចជឿទុកចិត្តបាន រួមមាន លក្ខណៈខាងក្នុង (ឧទាហរណ៍ ចំណុចសម្គាល់អក្សរសម្ងាត់ឯកសារយោង អ្នកនិពន្ធដែលស្គាល់អត្តសញ្ញាណ ភាពស៊ីសង្វាក់គ្នាខាងក្នុងនៅក្នុងខ្លឹមសារឯកសារ) និងលក្ខណៈខាងក្រៅ (ឧទាហរណ៍ បមាណីកម្ម អត្តសញ្ញាណកម្ម និងការរកឃើញ))។

[6] បញ្ជីឯកសារ និងវត្ថុតាងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានធ្វើបច្ចុប្បន្នភាព ស្របតាមវិធាន ៨០ សម្រាប់សំណុំរឿង ០០២/០២ ជាមួយឧបសម្ព័ន្ធសម្ងាត់ V ឯកសារ **E305/14** ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤ និងឧបសម្ព័ន្ធសម្ងាត់ V បញ្ជីឯកសារ និងវត្ថុតាងដែលបានធ្វើបច្ចុប្បន្នភាព ឯកសារ **E305/14.1.1**។

[7] សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨៧(៤) ដែលស្នើសុំទទួលយកជាភស្តុតាងនូវសក្ខីកម្មផ្ទាល់មាត់ និង ឯកសារ ព្រមទាំងវត្ថុតាង ដែលពាក់ព័ន្ធនឹងសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើសុំឱ្យមកផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ ឯកសារ **E307/6** ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤។

ការវិភាគដែលមានសំអាងហេតុ ទាក់ទិនទៅនឹងឯកសារដែលបានរាយឈ្មោះនៅក្នុងបញ្ជីនោះឡើយ ក្រៅតែពីការបែងចែងឯកសារទាំងនោះទៅតាមគូឡោន ដែលជំទាស់តវ៉ាអំពីកម្រិតនៃភាពជាប់ពាក់ព័ន្ធទៅនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ នៃឯកសារទាំងនោះ។

4. ទីមួយ សហមេធាវីនាំមុខឆ្លើយតបថា ឯកសារដែលត្រូវបានជំទាស់ភាគច្រើន ត្រូវបានចាត់ចំណាត់ថ្នាក់ជាឯកសារលេខ E3 ហើយត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ រួចហើយ។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ "សំណុំរឿង ០០២ ស្ថិតនៅដដែល សម្រាប់ដំណាក់កាលទាំងពីរនៃការជំនុំជម្រះ ហើយភ័ស្តុតាងដែលបានដាក់រួចហើយនៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ ត្រូវយកមកប្រើប្រាស់ជាមូលដ្ឋានសម្រាប់សំណុំរឿង ០០២/០២។ ការចាត់ឯកសារលេខ E3 ជាឯកសារភ័ស្តុតាង ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១ នឹងនៅដដែលសម្រាប់សំណុំរឿង ០០២/០២"[8]។ ដូច្នេះ ឯកសារទាំងនោះត្រូវបានកំណត់ *តាមការវិភាគបឋម* (*prima facie*) ថាមានភាពជាប់ពាក់ព័ន្ធ គួរឱ្យជឿជាក់បាន និងមានតម្លៃជាភ័ស្តុតាង។

5. ទីពីរ សហមេធាវីនាំមុខបានកំណត់រួចហើយថា ឯកសារដែលត្រូវបានជំទាស់ និងមាននៅក្នុង *បញ្ជីឯកសារ និងវត្ថុតាងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានធ្វើបច្ចុប្បន្នភាព ស្របតាមវិធាន ៨០ សម្រាប់សំណុំរឿង ០០២/០២ ជាមួយឧបសម្ព័ន្ធសម្ងាត់ V*[9] ស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២។ ឧបសម្ព័ន្ធ V[10] នៃសារណាទាំងនេះ ផ្តល់នូវការពិពណ៌នាសង្ខេបអំពីលក្ខណៈ និងខ្លឹមសារនៃឯកសារទាំងនោះ ព្រមទាំងការយោងជាក់លាក់ទៅនឹងចំណុចពាក់ព័ន្ធនានានៃការចោទប្រកាន់ សម្រាប់ឯកសារនីមួយៗដែលបានស្នើឡើង

---

[8] អនុស្សរណៈ អង្គជំនុំជម្រះសាលាដំបូង៖ ការបញ្ជាក់បំភ្លឺទាក់ទងទៅនឹងការប្រើប្រាស់ភ័ស្តុតាង និងនីតិវិធីដើម្បីកោះហៅសាក្សីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសាជាថ្មីឡើងវិញពីសំណុំរឿង ០០២/០១ សម្រាប់សំណុំរឿង ០០២/០២ ឯកសារ **E302/5** ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ កថាខណ្ឌ ៧។

[9] បញ្ជីឯកសារ និងវត្ថុតាងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានធ្វើបច្ចុប្បន្នភាព ស្របតាមវិធាន ៨០ សម្រាប់សំណុំរឿង ០០២/០២ ជាមួយឧបសម្ព័ន្ធសម្ងាត់ V ឯកសារ **E305/14** ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤ និង ឧបសម្ព័ន្ធសម្ងាត់ V បញ្ជីឯកសារ និងវត្ថុតាងដែលបានធ្វើបច្ចុប្បន្នភាព ឯកសារ **E305/14.1.1**។

[10] ឧបសម្ព័ន្ធសម្ងាត់ V បញ្ជីឯកសារ និងវត្ថុតាងដែលបានធ្វើបច្ចុប្បន្នភាព ឯកសារ **E305/14.1.1** ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤។

អនុលោមតាម*ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីរៀបចំសវនាការក្នុងសំណុំរឿង ០០២/០២* របស់អង្គជំនុំជម្រះសាលាដំបូង[11]។

6. ទីបី ពាក់ព័ន្ធនឹងឯកសារចំនួនបីដែលត្រូវបានជំទាស់ ដែលមាននៅក្នុងសំណើទាក់ទិននឹងឯកសារថ្មីរបស់សហមេធាវីនាំមុខ[12] សហមេធាវីនាំមុខកត់សម្គាល់ថា មេធាវីការពារក្តីបង្ហាញការជំទាស់ទៅនឹងភាពជាប់ពាក់ព័ន្ធនៃឯកសារទាំងនេះទៅនឹងវិសាលភាពនៃសំណុំរឿង ០០២/០២។ សហមេធាវីនាំមុខបានបញ្ជាក់ឡើងវិញអំពីសារណារបស់ខ្លួន ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ និងរម្លឹកថា៖ (i) ឯកសារ E307/6.1.2 ដែលជាព័ត៌មានបន្ថែមរបស់សាក្សី 2-TCCP-286 ទាក់ទិនទៅនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ដើមបណ្តឹងរដ្ឋប្បវេណី[13] (ii) ឯកសារ E307/6.1.3 ដែលជាការនិយាយរៀបរាប់ផ្តល់ចម្លើយដោយមានជំនួយពីអ្នកជំនាញផ្លូវចិត្តរបស់សាក្សី 2-TCCP-283 ពិពណ៌នាអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការរួមភេទដោយបង្ខំ ការកំណត់គោលដៅស្ត្រីជនជាតិវៀតណាមភាគតិចសម្រាប់អំពើហិង្សាលើផ្លូវភេទ[14] និង (iii) ឯកសារ E307/6.1.10 ដែលជាព័ត៌មានបន្ថែមរបស់សាក្សី 2-TCCP-267 ពិពណ៌នាអំពីបទពិសោធន៍របស់ដើមបណ្តឹង

---

[11] ដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងឲ្យភាគីដាក់សម្ភារដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីរៀបចំសវនាការក្នុងសំណុំរឿង ០០២/០២ ឯកសារ **E305** ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៤ កថាខណ្ឌ ១១-១២។

[12] ការជំទាស់ កំណត់ឯកសារ **E307/6.1.2** ឯកសារ **E307/6.1.3** និងឯកសារ **E307/6.1.10** ថាផ្នែកខ្លះស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០២។ សូមមើល Annexe B – Exceptions d'irrecevabilité relatives aux documents proposés par les Parties civiles ឯកសារ **E327/3.3** ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៥។

[13] សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨៧(៤) ដែលស្នើសុំទទួលយកជាភស្តុតាងនូវសេចក្តីកម្មផ្ទាល់មាត់ និង ឯកសារ ព្រមទាំងវត្ថុតាង ដែលពាក់ព័ន្ធនឹងសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើសុំឲ្យមកផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ ឯកសារ **E307/6** ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ កថាខណ្ឌ ៣០ និង ៣១។

[14] សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨៧(៤) ដែលស្នើសុំទទួលយកជាភស្តុតាងនូវសេចក្តីកម្មផ្ទាល់មាត់ និង ឯកសារ ព្រមទាំងវត្ថុតាង ដែលពាក់ព័ន្ធនឹងសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើសុំឲ្យមកផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ ឯកសារ **E307/6** ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ កថាខណ្ឌ ៣៧ និង ៣៨។

រដ្ឋប្បវេណីនៅឯមន្ទីរ ស-២១ និងអាពាហ៍ពិពាហ៍ដោយបង្ខំរបស់អ្នកស្រី[15]។ ការដាក់បទបញ្ជាអំពីការរៀបអាពាហ៍ពិពាហ៍ ការកំណត់គោលដៅជនជាតិវៀតណាមភាគតិច និងមន្ទីរ ស-២១ ពិតជាស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២[16]។

7. ទីបួន សហមេធាវីនាំមុខអះអាងថា វាមិនសមស្របឡើយក្នុងការមានសវនាការផ្ទាល់មាត់ ទាក់ទិននឹងតម្លៃជាភ័ស្តុតាងនៃឯកសារទាំងនេះនៅដំណាក់កាលដំបូងបែបនេះ។ សហមេធាវីនាំមុខកត់សម្គាល់ថា “នៅក្នុងការសម្រេចសេចក្តី អង្គជំនុំជម្រះនឹងពឹងផ្អែកទៅលើភ័ស្តុតាង ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងដាក់ឲ្យពិភាក្សាដេញដោលតទល់គ្នា”[17]។ ដោយសារតែឯកសារមួយចំនួន ទាក់ទិននឹងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានស្នើឡើងដើម្បីឲ្យផ្តល់សក្ខីកម្មនោះ វាជាការឆាប់រហ័សពេកក្នុងការជំទាស់អំពីតម្លៃជាភ័ស្តុតាងនៃឯកសារទាំងនោះនៅដំណាក់កាលនេះ។ សហមេធាវីនាំមុខកត់សម្គាល់ថា ទោះបីជាយ៉ាងណាក៏ដោយ ឯកសារដែលមិនត្រូវបានដាក់ឲ្យមានការដេញដោលពីភាគីនានានៅក្នុងតុលាការ អាចត្រូវបានទទួលយក និងផ្តល់តម្លៃជាភ័ស្តុតាង ប្រសិនបើឯកសារទាំងនោះមានលក្ខណៈត្រូវគ្នា ពាក់ព័ន្ធទៅនឹងភ័ស្តុតាងនៃកន្លែងដែលឧក្រិដ្ឋកម្មបានកើតឡើង ឬពាក់ព័ន្ធទៅនឹងផលប៉ះពាល់លើជនរងគ្រោះ[18]។ ក្រោយមកទៀត អង្គជំនុំជម្រះត្រូវវាយតម្លៃថាតើនឹងត្រូវផ្តល់តម្លៃជាភ័ស្តុតាងត្រឹមកម្រិតណា ទៅឲ្យឯកសារដែលត្រូវបានទទួលយកនេះ ប្រសិនបើត្រូវផ្តល់[19]។

---

[15] សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨៧(៤) ដែលស្នើសុំទទួលយកជាភស្តុតាង នូវសក្ខីកម្មផ្ទាល់មាត់ និង ឯកសារ ព្រមទាំងវត្ថុតាង ដែលពាក់ព័ន្ធនឹងសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើសុំឲ្យមកផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ ឯកសារ **E307/6** ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ កថាខណ្ឌ ៥៤។

[16] សូមមើល សេចក្តីសម្រេចលើវិសាលភាពនៃសំណុំរឿង ០០២/០២ ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយ ដែលទាក់ទងនឹងការជំនុំជម្រះសំណុំរឿងលេខ ០០២/០២ ឯកសារ **E301/9/1.1** ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤។

[17] សាលក្រម សំណុំរឿង ០០២/០១ ឯកសារ **E313** ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៣៤។

[18] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី ឯកសារ **E96/7** ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ២៤។

[19] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី ឯកសារ **E96/7** ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ២៥។

8. ចុងក្រោយ ទាក់ទិនទៅនឹងស្ថានភាពនៃការបកប្រែឯកសារដែលបានស្នើឡើងដោយសហមេធាវីនាំមុខនោះ ឯកសារទាំងអស់ដែលត្រូវបានកំណត់នៅក្នុងឯកសារ E305/14 និងឯកសារ E307/6 ត្រូវបានស្នើសុំរួចហើយដើម្បីធ្វើការបកប្រែ ឬក៏កំពុងស្ថិតនៅក្នុងដំណើរការដាក់ស្នើសុំបកប្រែ។

## IV. **សំណើ**

**អាស្រ័យហេតុនេះ** សហមេធាវីនាំមុខ ស្នើសុំដោយគោរពដល់អង្គជំនុំជម្រះសាលាដំបូងមេត្តា៖

(១) **បដិសេធ** ការជំទាស់នេះ។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ | វ៉ែន ពៅ<br>សហមេធាវីនាំមុខស្ដីទី | ភ្នំពេញ | |
| | Marie GUIRAUD<br>សហមេធាវីនាំមុខ | ភ្នំពេញ | |